ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌

លេខ : ១៥៨ កយ.ប្រក/២១

# ប្រកាស
# ស្តីពី
# ការប្រឡងប្រជែងជ្រើសរើសសិស្សចៅក្រម ជំនាន់ទី ១១ នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
## និងជាប្រធានក្រុមប្រឹក្សាភិបាលនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៦ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១០៥/០១៩ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០០៥ ស្តីពីការបង្កើតរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៣/១០៥៨ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៣ ស្តីពីការផ្ទេររាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការឲ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ២៤០ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ០៩ អនក្រ.បក ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០០២ ស្តីពី ការបង្កើតសាលាភូមិន្ទចៅក្រម



មហាវិថីសម្តេចសុធារស.ខ័ណ្ឌដូនពេញ.រាជធានីភ្នំពេញ ទូរស័ព្ទ : 023 216 322, 023 217 841, 023 212 693

- យោងលិខិតលេខ ២០០២ កយ.រប/១៦ ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៦ របស់ក្រសួងយុត្តិធម៌ និង ចំណារឯកភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** នៃ ព្រះរាជាណាចក្រកម្ពុជា
- យោងកំណត់ហេតុកិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី ២០ នាថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២១ របស់រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ

# សម្រេច

**ប្រការ ១**.- បើកឲ្យមានការប្រឡងប្រជែងជ្រើសរើស**សិស្សចៅក្រម ជំនាន់ទី ១១** នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ **ចំនួន ៥០ នាក់** ដោយធ្វើការប្រឡងប្រជែងជ្រើសរើសក្នុងចំណោមមន្ត្រីរាជការ និង និស្សិត។

**ប្រការ ២**.- ការប្រឡងប្រជែងជ្រើសរើស**សិស្សចៅក្រម ជំនាន់ទី ១១** នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ មានពីរដំណាក់កាលៈ

ដំណាក់កាលទី ១: ការប្រឡងប្រជែងលើវិញ្ញាសាសរសេរ មានចំនួន ០២ មុខវិជ្ជា គឺ:

- **នីតិព្រហ្មទណ្ឌ** (នីតិព្រហ្មទណ្ឌទូទៅ នីតិព្រហ្មទណ្ឌពិសេស) **និងនីតិវិធីព្រហ្មទណ្ឌ** រយៈពេល ០៣ ម៉ោង មេគុណ ១
- **នីតិរដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី** រយៈពេល ០៣ ម៉ោង មេគុណ ១

ករណីបើបេក្ខជនអវត្តមានក្នុងការប្រឡងប្រជែង ចំពោះវិញ្ញាសាណាមួយក្នុងចំណោមមុខវិជ្ជាទាំងពីរខាងលើ នឹងត្រូវធ្លាក់ដោយស្វ័យប្រវត្តិ។

ការប្រឡងប្រជែងលើវិញ្ញាសាសរសេរខាងលើនឹងប្រព្រឹត្តិទៅនៅ**ថ្ងៃចន្ទ ទី២២ ខែវិច្ឆិកា ឆ្នាំ ២០២១**។

ដំណាក់កាលទី ២: ការប្រឡងប្រជែងលើវិញ្ញាសាសួរផ្ទាល់មាត់ មានចំនួន ០២ មុខវិជ្ជា គឺ:

- **វប្បធម៌ទូទៅ** (ពាក់ព័ន្ធវិស័យច្បាប់ និងយុត្តិធម៌) មេគុណ ២
- **នីតិភូមិបាល នីតិការងារ និងនីតិពាណិជ្ជកម្ម** (នីតិក្រុមហ៊ុន នីតិកម្មសិទ្ធិបញ្ញា និង ច្បាប់ពាណិជ្ជកម្មផ្សេងទៀត) មេគុណ ១

  ចំពោះមុខវិជ្ជា នីតិភូមិបាល នីតិការងារ និងនីតិពាណិជ្ជកម្ម បេក្ខជនត្រូវជ្រើសរើសយកមុខវិជ្ជាមួយក្នុងចំណោមមុខវិជ្ជាទាំង ៣ សម្រាប់ឆ្លើយនឹងសំណួររបស់គណៈមេប្រយោគ។ ប្រសិនបើយល់ឃើញថាមានការចាំបាច់នោះ គណៈមេប្រយោគអាចសួរសំណួរទៅបេក្ខជនលើមុខវិជ្ជា ២ ផ្សេងទៀតបាន។

រយៈពេលសម្រាប់ត្រៀម, សួរ និងឆ្លើយសំណួរត្រូវកំណត់ដោយគណៈកម្មការនាយក។

ចំពោះកាលបរិច្ឆេទនៃការប្រឡងប្រជែងវិញ្ញាសាសួរផ្ទាល់មាត់ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការនឹងជូនដំណឹងនៅពេលក្រោយ។

**ប្រការ ៣**.- បែបបទ និងលក្ខខណ្ឌនៃការប្រឡងប្រជែងជ្រើសរើស៖

ក- បេក្ខជនទាំងពីរភេទ ត្រូវមានសញ្ញាតិខ្មែរពីកំណើត។

ខ- ត្រូវមានអាយុ ៣៥ ( សាមសិបប្រាំ ) ឆ្នាំយ៉ាងច្រើន ចំពោះបេក្ខជនជានិស្សិត និងមានអាយុ ៤០ (សែសិប) ឆ្នាំយ៉ាងច្រើន ចំពោះបេក្ខជនជាមន្ត្រីរាជការគិតមកដល់ថ្ងៃប្រឡង។

គ- ត្រូវមានសញ្ញាបត្របរិញ្ញាបត្រច្បាប់ឡើងទៅ។

ឃ- ត្រូវមានលិខិតថ្កោលទោសចេញពីក្រសួងយុត្តិធម៌បញ្ជាក់ថា មិនធ្លាប់មានទោសពីបទមជ្ឈិម ឬបទឧក្រិដ្ឋ។

ង- ត្រូវមានលិខិតបញ្ជាក់សុខភាពចេញដោយពេទ្យការងារនៃក្រសួងការងារ និងបណ្តុះ-បណ្តាលវិជ្ជាជីវៈ។

ច- ត្រូវមានឈ្មោះក្នុងបញ្ជី ប្រកាសស្តីពី ការទទួលស្គាល់បេក្ខជនអនុញ្ញាតឲ្យចូលប្រឡងប្រជែងជ្រើសរើស**សិស្សចៅក្រម ជំនាន់ទី ១១**។

ឆ- បេក្ខជនត្រូវមានប័ណ្ណចាក់វ៉ាក់សាំងកូវីដ-១៩ ឬលិខិតបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច។ ក្នុងករណីបេក្ខជនមិនទាន់បានចាក់វ៉ាក់សាំងកូវីដ-១៩ ត្រូវមានលិខិតបញ្ជាក់ពីមូលហេតុ ដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច។

ជ- បេក្ខជនត្រូវមកធ្វើតេស្តរកអង់ទីហ្សែនកូវីដ-១៩ តាមការកំណត់របស់គណៈកម្មការរៀបចំការប្រឡង។ ក្នុងករណីបេក្ខជនខកខានមិនបានមកធ្វើតេស្តតាមកាលកំណត់ ឬតេស្តឃើញលទ្ធផលវិជ្ជមានកូវីដ-១៩ មិនត្រូវបានអនុញ្ញាតឱ្យចូលរួមការប្រឡងប្រជែងឡើយ។

**ប្រការ ៤**.- សមាសភាពគណៈមេប្រយោគ និងគណៈកម្មការនានា ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់គណៈកម្មការនាយក។

**ប្រការ ៥**.- រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ អគ្គលេខាធិការដ្ឋាន គ្រប់សាលាភូមិន្ទ នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ អគ្គលេខាធិការដ្ឋាន គ្រប់អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋានកិច្ចការតុលាការ និងអង្គភាពនានាចំណុះក្រសួងយុត្តិធម៌ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៧កើត ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ,ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងជាប្រធាន**

**ក្រុមប្រឹក្សាភិបាលនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ**

ក្រសួងយុត្តិធម៌

**កើត រិទ្ធ**

**កន្លែងទទួល** :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ដូចប្រការ ៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ